**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ** ...............១៤៥............ក.ប/ស.ណ.ណា

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារថា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ សំដៅដល់ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាពិសេសការរៀបចំ និងដាក់ឲ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកសោធន ក្រសួងតម្រូវឲ្យចុះបញ្ជិកាកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមឡើងវិញ។

កន្លងមកក្រសួងសង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួន អំពីអត្តសញ្ញាណរបស់កម្មករនិយោជិត ដូចជា ការខ្ចីឈ្មោះអ្នកដទៃប្រើ, ការខុសឈ្មោះ, ការខុសភេទ, ការខុសថ្ងៃខែឆ្នាំកំណើត, ការខុសទីកន្លែងកំណើតជាដើម ដែលអាចបង្កឲ្យលេចចេញនូវបាតុភាពមិនប្រក្រតីនានា ធ្វើឲ្យភាគីពាក់ព័ន្ធជាពិសេស និយោជក និងកម្មករនិយោជិត មានការព្រួយបារម្ភចំពោះផលប៉ះពាល់តាមផ្លូវច្បាប់នានា ទាក់ទងនឹងការក្លែងឯកសារ, ការបាត់បង់អតីតភាពការងារ, ការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ, សៀវភៅការងារ, បញ្ជិកាអង្គការវិជ្ជាជីវៈ ការបណ្តេញចេញពីការងារ ការចោទប្រកាន់ចំពោះការប្រើប្រាស់ពលកម្មកុមារ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ និងចៀសវាងនូវរាល់បាតុភាពជាយថាហេតុ ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពដែលពាក់ព័ន្ធ ត្រូវអនុវត្តដូចខាងក្រោម៖

១.មិនត្រូវចាត់ទុកជាកំហុស ចំពោះគ្រប់រូបភាពមិនប្រក្រតីខាងលើរបស់កម្មករនិយោជិត។

២.នៅពេលចុះបញ្ជិកាឡើងវិញ កម្មករនិយោជិតដែលមានបញ្ហាដូចខាងលើ ត្រូវបានរក្សានូវសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗ ដូចជា អតីតភាពការងារ តួនាទីក្នុងអង្គការវិជ្ជាជីវៈ និងកិច្ចសន្យាការងារ។

៣.និយោជក មិនត្រូវទទួលបានការចោទប្រកាន់ថាប្រើប្រាស់ពលកម្មកុមារ ចំពោះករណីដែលកម្មករនិយោជិតប្រើអត្តសញ្ញាណខុសប្រក្រតីនេះទេ។

៤.កម្មករនិយោជិត ដែលទទួលបានការធ្វើនិយ័តកម្មអត្តសញ្ញាណឲ្យបានត្រឹមត្រូវឡើងវិញ មិនតម្រូវឲ្យមានការបង់ថ្លៃសេវាពិនិត្យកាយសម្បទា, បណ្ណការងារ សៀវភៅការងារ និងបញ្ជិកាអង្គការវិជ្ជាជីវៈ ចំពោះរាល់ការធ្វើនិយ័តកម្មឯកសារនេះឡើងវិញ។

៥.ក្នុងការជ្រើសរើសកម្មករនិយោជិតថ្មី សហគ្រាស គ្រឹះស្ថានចាំបាច់ត្រូវទាមទារឯកសារបញ្ជាក់អត្តសញ្ញាណរបស់សាមីខ្លួន ដូចជា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតឆ្លងដែន ឲ្យបានត្រឹមត្រូវ។

នៅក្នុងដំណើរការនៃការចុះបញ្ជិកាឡើងវិញ កម្មករនិយោជិត ត្រូវបំពេញសលាកបត្រព័ត៌មាន និងមានឯកសារផ្ទាល់ខ្លួនសំខាន់ៗ រួមមាន អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន សេចក្តីចម្លងសំបុត្រកំណើត សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និងអង្គភាពពាក់ព័ន្ធនឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**